Second AC
Judgem
SC

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៦៣១
ចុះថ្ងៃទី២៨.១០.២០២០
សាលដីកា
លេខ: ១០៥ ក្រVI.ត.ស
ចុះថ្ងៃទី២០.១០.២០២១

## គាទនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ភ្នំពេញនាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

អគ្គា [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៦៣១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] វតនា ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករជាងចក្រ មានទីកន្លែងកំណើតនៅសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួននៅបន្ទប់ជួល [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ជាឪតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ២៤៧ "ជ" ៨.ឃ.ង ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ ។

២-ជនជាប់ចោទឈ្មោះ [redacted] ធារី ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិមេសប្រច័ន្ទ ឃុំមេសប្រច័ន្ទ ស្រុកពារាំង ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួននៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងលាភ [redacted] ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ជាឪតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ២៤៤ "ជ" ៨.ឃ.ង ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨។

៣-ជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរ ... មានទីកន្លែងកំណើតនៅភូមិពោធិ៍សាលា១ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួននៅ





Scanned with CamScanner

បន្ទប់ជួលក្នុងផ្ទះសំណាក់ចឹងលាភ [redacted]ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] គ្មានកូន ជាទីតិជន ទោសពីមុន គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ២៤៦ "ធ" ៥.ឃ.ង ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨។

Heas Bora

៤-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មាន ទីកន្លែងកំណើតនៅភូមិពោធិ៍សាលា១ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ជាទីតិជន ទោសពីមុន គ្មាន។ ប្តឹងសាទុក្ខ

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ២៤៥ "ធ" ៥.ឃ.ង ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨។

មានមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ។

ជាប់ចោទពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ឯរឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅចំណុចរាជធានីភ្នំពេញ បានកើតមានករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយកើតឡើង ដែលអំពើនេះបង្កឡើងដោយជនជាប់ចោទ ១.ឈ្មោះ [redacted] រតនា ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ, ២.ឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ, ៣.ឈ្មោះ [redacted] បូរ៉ា ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ និង៤.ឈ្មោះ [redacted] ធារី ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ដែកឆែរឃើញមានថ្នាំញៀន រួមទាំងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន ០១។ នៅពេលឃាត់ខ្លួនជនជាប់ចោទខាង លើ បានឆ្លើយសារភាពថា ថ្នាំញៀនគឺ ពួកខ្លួនទិញពីឈ្មោះ ណាក់ ហៅ ខ្មៅ ភេទប្រុស និងឈ្មោះ ធៀ រួចសមត្ថកិច្ច ក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

ចំពោះជនជាប់ចោទ ១.ឈ្មោះ [redacted] រតនា ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ, ២.ឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ, ៣.ឈ្មោះ [redacted] បូរ៉ា ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ និង៤.ឈ្មោះ [redacted] ធារី ហៅ ដា ភេទស្រី អាយុ២០ឆ្នាំ ត្រូវសមត្ថកិច្ចពិនិត្យទឹកនោម ឃើញមានសារធាតុញៀន។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ: ៧១៥ ក្រ១១ "ឃ១" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់ សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសលើជនជាប់ចោទ:

ក.ឈ្មោះ [redacted] រតនា ហៅ ហ៊ីម ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ចំនួន ៥ (ប្រាំ) ឆ្នាំ។

ខ.ឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ

គ.ឈ្មោះ [redacted] បូរ៉ា ហៅ ម៉ាប់ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ

ឃ.ឈ្មោះ [redacted] ធារី ហៅ ដា ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ចំនួន ៦ (ប្រាំមួយ) ឆ្នាំ។

ពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យកដែលត្រូវរឹបអូសមាន៖

១,ស្រោមសំបុត្រពណ៌ស មានក្រាមថ្នាំទម្ងន់ ២,៨១g (ពីរក្បៀសប៉ែតសិបមួយក្រាម) ជារបស់ជនជាប់ចោទឈ្មោះ [redacted] រតនា។

២,ស្រោមសំបុត្រពណ៌ស មានក្រាមថ្នាំពណ៌សទម្ងន់ ២៥,០៣g (ម្ភៃប្រាំក្បៀសសូន្យបីក្រាម) ជារបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត, ឈ្មោះ [redacted] ប៉ូវ៉ា និងឈ្មោះ [redacted] ធារី។

៣,ទូរស័ព្ទដៃចំនួន ០៣គ្រឿង ម៉ាកហួវ៉ាយ (HUAWEI) និង០២គ្រឿងទៀត ម៉ាកណូគាខ្មៅចុចពិលចំនួន ០១គ្រឿង ពណ៌សចំនួន ០១គ្រឿង។

៤,ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន ០១គ្រឿង។

៥,ក្រដាសអាលុយមីញ៉ូមចំនួន ០១ដុំតូច ៦,ដបសម្រាប់ដក់គ្រឿងញៀនចំនួន ០៤, និង៧ ដែកកេះចំនួន០១។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ហ៊ឹម, ឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ, ឈ្មោះ [redacted] ប៉ូវ៉ា ហៅ ម៉ាច់ និងឈ្មោះ [redacted] ធារី ហៅ ដា ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ: ៦៧៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៧១៥ ក្រ១១ "ឃ១" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ: ៦៧៦ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ របស់មេធាវី [redacted] ក្នុងនាមទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត និងឈ្មោះ [redacted] ប៉ូវ៉ា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៧១៥ ក្រ១១ "ឃ១" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ: ៦៨១ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ប៉ូវ៉ា ហៅ ម៉ាច់ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៧១៥ ក្រ១១ "ឃ១" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ: ៧៣៧ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ធារី សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៧១៥ ក្រ១១ "ឃ១" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។



Scanned with CamScanner

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខៈ ០២ ក្រII "ញ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែ៩ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ស៊ីវ៉ាត និងលោកស្រី [redacted] ភូឡាប ជាមេធាវីការពារឱ្យឈ្មោះ [redacted] ស៊ីវ៉ាត, ឈ្មោះ [redacted] ប៊ូវ៉ា ហៅ ម៉ាប់, បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែ៩ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ប៊ូវ៉ា និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២២ ខែ១០ ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ថាវី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៧១៥ "ឃ១" ក្រII ចុះថ្ងៃទី២១ ខែ៩ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែត្រង់ចំណុចទី១ ក.ខ.ឃ ត្រង់ចំណុច "ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ" ត្រូវកែប្រែមកជា "ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៥ឆ្នាំវិញ"។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត ឈ្មោះ [redacted] ប៊ូវ៉ា និងឈ្មោះ [redacted] ថាវី។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០។

-ទុកសិទ្ធិឱ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខៈ ១៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ូវ៉ា សុំប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខៈ ០២ ក្រII "ញ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខៈ ៣៣៣ IV ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងសាទុក្ខលេខៈ ១៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ូវ៉ា។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខៈ ០២ ក្រII "ញ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់សេចក្តីសម្រេចដែលបានតម្កល់ចំណុចទី១.គ នៃសាលក្រមព្រហ្មទណ្ឌលេខ ៧១៥ ក្រ១១ "ឃ១" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៤៤ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះឡើងវិញ ត្រង់ចំណុចដែលត្រូវបានបដិសេធដូចខាងលើ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០។

**<u>សំអាងហេតុរបស់តុលាការកំពូលត្រង់ចំណុចទី៣ បានលើកឡើងថា</u>**

ការដែលសាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញដែលបានយល់ឃើញថា ជនជាប់ចោទមានពិរុទ្ធភាពពីបទ ជួញដូរ និងប្រើប្រាស់សារធាតុញៀនដោយខុសច្បាប់ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ដោយសំអាងទៅលើចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ូវ៉ា នៅដំណាក់កាលនគរបាលយុត្តិធម៌នោះ មិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយ ព្រោះថា តាមចម្លើយរបស់ជនជាប់ចោទ [redacted] ប៊ូវ៉ា នៅដំណាក់កាលនគរបាលយុត្តិធម៌ថា កន្លងមកខ្លួនធ្លាប់ទៅលេងនៅបន្ទប់ស្នាក់នៅរបស់ឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ [illegible] ហើយត្រូវបានឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ ប្រើឱ្យយកគ្រឿងញៀនទៅលក់ឱ្យគេបានចំនួន ០២ដង [illegible]

បានលុយយកឱ្យឈ្មោះ [redacted] ស៊ីវ៉ាត ទាំងអស់ ហើយឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ បានឱ្យប្រាក់ឈ្នួលពីការលក់គ្រឿងញៀនមកខ្លួនចំនួន ៥ ០០០ រៀល ទៅ ១០ ០០០ រៀល និងឱ្យគ្រឿងញៀនប្រើប្រាស់មួយចំនួន ឃើញថាចម្លើយនេះពាក់ព័ន្ធនឹងរឿងហេតុដែលបានកើតឡើងកន្លងមក ប៉ុន្តែអង្គហេតុនៃការជួញដូរគ្រឿងញៀន និងផ្គត់ផ្គង់គ្រឿងញៀនកើតឡើងនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នេះ មិនអាចយកអង្គហេតុមុនមកកំណត់ពិរុទ្ធភាពលើជនជាប់ចោទដែលបានប្រព្រឹត្តនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បានទេ។ ដូច្នេះ តុលាការអង្គហេតុគប្បីធ្វើការស្រាវជ្រាវឱ្យបានច្បាស់លាស់ទៅលើអង្គហេតុនៃការចោទប្រកាន់ដែលពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] ប្ញាំ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នេះ។ ម្យ៉ាងវិញទៀត ជនជាប់ចោទបានឆ្លើយបញ្ជាក់ថា នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ខ្លួនគ្រាន់តែបានមកបន្ទប់ជួលរបស់ឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ នៅពេលព្រឹក ហើយក៏ត្រូវសមត្ថកិច្ចចុះឆែកឆេរបន្ទប់ និងឃាត់ខ្លួនតែម្តងនៅពេលរសៀល ដែលជនជាប់ចោទ [redacted] ប្ញាំ អះអាងថា មិនបានចូលរួមប្រព្រឹត្តទេ ដែលគប្បីធ្វើការពិនិត្យ និងស្រាវជ្រាវបន្ថែមឱ្យបានច្បាស់លាស់ មុននឹងកំណត់ពិរុទ្ធភាព។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] ប្ញាំ (វត្តមាន)

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ (វត្តមាន)

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] ប្ញាំ ឆ្លើយបដិសេធថា: ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ស៊ីវ៉ាត ព្រោះគាត់ជាអ្នកស្រុកភូមិជាមួយខ្លួន ហើយនៅពេលព្រឹកថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ខ្លួនបានធ្វើដំណើរពីស្រុកកំណើតខេត្តកំពង់ចាមមកភ្នំពេញដើម្បីរកការងារធ្វើ ក៏ចូលលេងឈ្មោះ [redacted] ស៊ីវ៉ាត ស្រាប់តែពេលល្ងាច ក៏មានសមត្ថកិច្ចចុះមកឆែកឆេរ និងឃាត់ខ្លួនតែម្តង។ ចំណែកឈ្មោះ [redacted] ថាវី ហៅ ដា ខ្លួនក៏ស្គាល់ដែរ ព្រោះគាត់គឺ ជាសង្សាររបស់ឈ្មោះ [redacted] ស៊ីវ៉ាត។ ខ្លួនទទួលស្គាល់ថា កន្លងមកខ្លួនធ្លាប់បានប្រព្រឹត្តមែន ប៉ុន្តែនៅថ្ងៃទី០៦ ខែមករា ឆ្នាំ ២០១៨ គឺខ្លួនមិនបានប្រព្រឹត្តនោះទេ។ ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ចគឺ ខ្លួនមិនទទួលស្គាល់ទេ ព្រោះសមត្ថកិច្ចបានវាយខ្លួន រីឯចម្លើយនៅសាលាដំបូង ខ្លួនទទួលស្គាល់។

សំណូមពរ សុំតុលាការជួយបន្ធូរបន្ថយទោស។

ក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត និងឈ្មោះ [redacted] ថាវី ៖

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ បានឆ្លើយនាពេលសវនាការនៅសាលាដំបូងថា: កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ខ្លួនបានចេញទៅក្រៅមិនបាននៅក្នុងបន្ទប់ជួលទេ នៅពេលខ្លួនត្រឡប់មកវិញស្រាប់តែឃើញមានសមត្ថកិច្ចកងរាជអាវុធហត្ថកំពុងធ្វើការឆែកឆេរនៅក្នុងបន្ទប់ជួលរបស់ខ្លួនលេខ២៣ ក្នុងផ្ទះសំណាក់បឹងលាភ ដែលខ្លួនចូលលុយគ្នាជាមួយឈ្មោះ [redacted] ថាវី ហៅ ដា ត្រូវជាសង្សារ និងឈ្មោះ [redacted] ប្ញាំ ស្នាក់នៅជាមួយគ្នាចំនួន ១០ថ្ងៃ។ នៅពេលឆែកឆេរសមត្ថកិច្ចបានរកឃើញថ្នាំញៀនចំនួន ០១កញ្ចប់ធំ, ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ និងឧបករណ៍សម្រាប់ជក់គ្រឿងញៀនចំនួន០១ ដែលឈ្មោះ [redacted] ថាវី និងឈ្មោះ [redacted] ប្ញាំ ទេតា ដ៏ប់ប្រាប់ខ្លួនថា ឈ្មោះ [redacted] រតនា ហៅ ហ៊ីម បានយកមកផ្ញើទុកនៅក្នុងបន្ទប់ខ្លួន រួចសមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួន និងសង្សារ([redacted] ថាវី) រួមជាមួយឈ្មោះ [redacted] ប្ញាំ នៅក្នុងបន្ទប់ជួលនោះតែម្តង។ កន្លងមកខ្លួនធ្លាប់ញៀនគ្រឿងញៀន

ឈ្មោះ ណាក់ ហៅ ម្មៅ ទិញម្តងៗ១ម្សៅ ៥ហ៊ុន តម្លៃ ២០០,០០០ (ម្ភៃម៉ឺន) រៀល និងពេលខ្លះទិញពីឈ្មោះ អៀ ទិញម្តងៗ១ម្សៅ ១ជី តម្លៃ ៤០០,០០០ (សែសិបម៉ឺន) រៀល គឺទិញសម្រាប់តែប្រើប្រាស់ជាមួយឈ្មោះ[redacted] ថាវី និងឈ្មោះ [redacted] ប្ញុនាំ ប៉ុណ្ណោះ ដោយការចូលលុយគ្នាទិញយកមកជក់។

-ជនជាប់ចោទឈ្មោះ [redacted] ថាវី ហៅ ដា បានឆ្លើយនាពេលសវនាការនៅសាលាដំបូងថា: កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ នៅពេលដែលខ្លួនស្នាក់នៅក្នុងបន្ទប់ជួលលេខ២៣ ក្នុងផ្ទះសំណាក់បឹងណារ៉ែលឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ ជាសង្សារជួលសម្រាប់ស្នាក់នៅជាមួយគ្នា និងស្នាក់នៅជាមួយឈ្មោះ [redacted] ប្ញុនាំ ស្រាប់តែសមត្ថកិច្ចកងរាជអាវុធហត្ថបានមកធ្វើការឆែកឆេរនៅក្នុងបន្ទប់ជួលនោះរកឃើញគ្រឿងញៀនចំនួន ០១កញ្ចប់, ដញ្ជក់សម្រាប់ជក់គ្រឿងញៀនចំនួន០១ ដែលជារបស់ពួកខ្លួនទាំងបីនាក់[redacted] ប្ញុនាំ, [redacted] ស៊ីវ៉ាត និងខ្លួន [redacted] ថាវី) រួចសមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួនទាំងបីនាក់តែម្តង។ ខ្លួន និងឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ ទើបតែស្គាល់គ្នាបានកន្លះខែប៉ុណ្ណោះ ក្រោយពីទាក់ទងគ្នាធ្វើសង្សារខ្លួនក៏ចេញពីស្រុកមករស់នៅជាមួយឈ្មោះ [redacted] ស៊ីវ៉ាត នៅក្នុងបន្ទប់ជួលលេខ២៣ នេះតែម្តង ដោយឈ្មោះ [redacted] ស៊ីវ៉ាត បានឱ្យខ្លួនចាយមួយថ្ងៃ ៤០,០០០ (បួនម៉ឺន) រៀល ទៅ ៥០,០០០ (ប្រាំម៉ឺន) រៀល ហើយខ្លួនក៏ចេះប្រើប្រាស់គ្រឿងញៀនដោយឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ ជាអ្នកឱ្យខ្លួនជក់ក្នុងមួយអាទិត្យម្តង ទៅ ពីរដង។

-តំណាងមហាអយ្យការ ធ្វើសេចក្តីសន្និដ្ឋានថា: ជនជាប់ចោទឈ្មោះ [redacted] ប្ញុនាំ ត្រូវបានជាប់ចោទពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ វត្ថុតាងចាប់យកដែលត្រូវវិភាគសមានក្រាមថ្លាពណ៌សទម្ងន់ ២៥,០៣ក្រាម គឺជារបស់ឈ្មោះ [redacted] ស៊ីវ៉ាត, ឈ្មោះ[redacted] ប្ញុនាំ និងឈ្មោះ[redacted] ថាវី។ ជនជាប់ចោទបានឆ្លើយបដិសេធចម្លើយរបស់ខ្លួននៅដំណាក់កាលនគរបាលយុត្តិធម៌ ប៉ុន្តែជនជាប់ចោទពុំមានអ្វីសំអាង ក្រៅតែពីពាក្យថាភ័យនោះទេ។ ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថាវី បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ប្ញុនាំ ពិតជាបានប្រព្រឹត្តបទល្មើសកាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ប្រាកដមែន។ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចតាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនឈ្មោះ [redacted] ប្ញុនាំ ពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយហេតុថា នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ កូនក្តីខ្លួនគ្រាន់តែបានចូលទៅក្នុងបន្ទប់របស់ឈ្មោះ [redacted] ស៊ីវ៉ាត នៅពេលព្រឹក ហើយស្រាប់តែពេលល្ងាចក៏មានសមត្ថកិច្ចចុះមកឆែកឆេរ និងឃាត់ខ្លួនតែម្តង។ ម្យ៉ាងវិញទៀត គ្រឿងញៀនដែលសមត្ថកិច្ចបានដកហូតនោះ ពុំមែនជារបស់កូនក្តីខ្លួននោះទេ ដូច្នេះយោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ។

សំណូមពរ សុំតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចមុខពីបទចោទ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប្ញុនាំ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត និងឈ្មោះ [redacted] ថាវី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ



Scanned with CamScanner

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា

១-តុលាការកំពូលបានសម្រេចបដិសេធសាលដីកាព្រហ្មទណ្ឌលេខ: ០២ ក្រ!! "ញ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់សេចក្តីសម្រេចដែលបានតម្កល់ចំណុចទី១.គ នៃសាលក្រមព្រហ្មទណ្ឌលេខ: ៧១៥ ក្រ១១ "ឃ១" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ និងបញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ: ៤៤ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ របស់តុលាការកំពូលមកសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទទួលសំណុំរឿងនេះជំនុំជម្រះបាន យោងតាមអំណាចសាលដីកាតុលាការកំពូល និងមាត្រា ៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តាមការចង្អុលបង្ហាញរបស់តុលាការកំពូល ត្រង់ការយល់ឃើញចំណុចទី៣ ផ្នែកសំអាងហេតុនៃសាលដីកាព្រហ្មទណ្ឌលេខ: ៣៣៣ IV ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ របស់តុលាការកំពូល បានលើកឡើងថា ការកំណត់ជនជាប់ចោទឈ្មោះ [redacted] ប្ញារ៉ា មានពិរុទ្ធភាពពីបទ ជួញដូរ និងប្រើប្រាស់សារធាតុញៀនដោយខុសច្បាប់ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ដោយសំអាងទៅលើចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលនគរបាលយុត្តិធម៌នោះ មិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយ គប្បីតុលាការអង្គហេតុធ្វើការស្រាវជ្រាវឱ្យបានច្បាស់លាស់ទៅលើអង្គហេតុនៃការចោទប្រកាន់ដែលពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] ប្ញារ៉ា នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨។ ការយល់ឃើញរបស់តុលាការកំពូលខាងលើនេះ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញលើកយកមកធ្វើការពិនិត្យ និងស្រាវជ្រាវបន្ថែមឱ្យបានច្បាស់លាស់មុននឹងកំណត់ពិរុទ្ធភាព និងសម្រេច យោងតាមបញ្ញត្តិមាត្រា ៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-តំណាងមហាអយ្យការ ធ្វើសេចក្តីសន្និដ្ឋានដោយសំណូមពរថា: ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថាវី បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ប្ញារ៉ា ពិតជាបានប្រព្រឹត្តបទល្មើសកាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ប្រាកដមែន។ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចតាមច្បាប់។

៤-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានដោយសំណូមពរថា: កូនក្តីខ្លួនឈ្មោះ [redacted] ប្ញារ៉ា ពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ សំណូមពរសុំតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា និងសម្រេចតាមច្បាប់។

៥-សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា: តាមចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] ប្ញារ៉ា គ្រាន់តែជាចម្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌប៉ុណ្ណោះ ជនជាប់ចោទពុំមានភស្តុតាងដោះបន្ទុកដើម្បីឱ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញជឿបានឡើយ។ រីឯតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ បានឆ្លើយសារភាពនៅសាលាដំបូងរាជធានីភ្នំពេញថា កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ សមត្ថកិច្ចកងរាជអាវុធហត្ថបានចុះមកឆែកឆេរនៅក្នុងបន្ទប់ជួលលេខ២៣ ក្នុងផ្ទះសំណាក់មិនស្គាល់ឈ្មោះ ដែលពួកខ្លួន(ឈ្មោះ [redacted] ស៊ីវ៉ាត, ឈ្មោះ [redacted] ថាវី និងឈ្មោះ [redacted] ប្ញារ៉ា) ជួលស្នាក់នៅជាមួយគ្នាបានចំនួន ១០ថ្ងៃ។ និងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថាវី បានឆ្លើយសារភាពនៅសាលាដំបូងរាជធានីភ្នំពេញថា [illegible]



Scanned with CamScanner

ទី០៦ ខែមករា ឆ្នាំ២០១៨ សមត្ថកិច្ចកងរាជអាវុធហត្ថបានចុះមកឆែកឆេរនៅក្នុងបន្ទប់ជួលលេខ២៣ ក្នុងផ្ទះសំណាក់បឹងឈូក ដែលឈ្មោះ [redacted] ស៊ីវ៉ាត, ឈ្មោះ [redacted] ប្ញារ៉ា និងខ្លួន ជួលស្នាក់នៅជាមួយគ្នា ដោយដកហូតបានគ្រឿងញៀនចំនួន ០១កញ្ចប់, ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០១ និងឧបករណ៍សម្រាប់ជក់គ្រឿងញៀនចំនួន០១ គឺជារបស់ពួកខ្លួនទាំងបីនាក់ (ឈ្មោះ [redacted] ស៊ីវ៉ាត, ឈ្មោះ [redacted] ថាវី និងឈ្មោះ [redacted] ប្ញារ៉ា)។ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា ចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់ខាងលើ មានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប្ញារ៉ា ដែលបានឆ្លើយបញ្ជាក់ពីសាវតាររបស់ខ្លួននៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា មុនពេលសមត្ថកិច្ចឃាត់ខ្លួន គឺខ្លួនស្នាក់នៅបន្ទប់ជួលក្នុងផ្ទះសំណាក់បឹងឈូក ស្ថិតនៅភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូច្នេះបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ប្ញារ៉ា ពិតជាបានជួលបន្ទប់ស្នាក់នៅរួមគ្នាជាមួយជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត និងឈ្មោះ [redacted] ថាវី នៅមុនថ្ងៃកើតហេតុរហូតដល់ថ្ងៃកើតហេតុប្រាកដមែន។

ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត ហៅ រាជ, ឈ្មោះ [redacted] ថាវី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ គឺបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ប្ញារ៉ា ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ ប្រាកដមែន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ សន្តិសុខសង្គម និងសុខភាពរបស់ប្រជាពលរដ្ឋយ៉ាងធ្ងន់ធ្ងរ ដែលគប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញផ្តន្ទាទោសលើជនជាប់ចោទរូបនេះតាមច្បាប់។

៦-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ: ១៣៥៧១/១៨ ម.ព.ស.ជ.ប.គ.ញ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានវត្តមានសារធាតុញៀន មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់ ៧៦,៥៨% និងក្រាមពណ៌សថ្លា ដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] ស៊ីវ៉ាត, ឈ្មោះ [redacted] ថាវី និងឈ្មោះ [redacted] ប្ញារ៉ា ទម្ងន់ ២៥,០៣ក្រាម ឃើញថា កម្រិតភាពសុទ្ធនៃសារធាតុញៀន មេតំហ្វេតាមីន $\frac{២៥.០៣ \times ៧៦.៥៨}{១០០}$ = ១៩,១៦ក្រាម។

៧-សាលដីកាព្រហ្មទណ្ឌលេខ: ០២ ក្រ៣ "ញ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់សេចក្តីសម្រេចដែលបានតម្កល់ចំណុចទី១.គ នៃសាលក្រមព្រហ្មទណ្ឌលេខ: ៧១៥ ក្រ១១ "ឃទ" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតុលាការកំពូលសម្រេចបដិសេធចោល ហើយ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញសម្រេចជាថ្មីតាមកម្រិតភាពសុទ្ធនៃសារធាតុញៀន។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៦៣១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ: ៣៣៣ IV ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ របស់តុលាការកំពូល និងមាត្រា ៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ខ-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ប្លាំ ហៅ ម៉ាច់ ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ, មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ។

លើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់ថ្នាក់គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted], [redacted], [redacted] [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២

បានឃើញ

ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ

ក្រឡាបញ្ជី

[redacted]